# ធនធានគោលនយោបាយ

**គោលនយោបាយ៖ ការបិទបញ្ចប់ពាក្យស្នើសុំត្រួតពិនិត្យតាមឆន្ទានុសិទ្ធិរបស់ស្ថាប័ន BRC ដោយសារតែការមិនឆ្លើយតប**
**កាលបរិច្ឆេទចូលជាធរមាន៖** 1 កុម្ភៈ 2024
តំណភ្ជាប់គោលនយោបាយ៖ https://www.mass.gov/doc/eec-closing-brc-discretionary-review-applications-due-to-non-response-policy-documentkhmer/download

ប្រសិនបើអ្នក ឬបុគ្គលិករបស់អ្នក មានសំណួរអំពីគោលនយោបាយនេះ ឬត្រូវការការគាំទ្របន្ថែម សូមទាក់ទងទៅកាន់មជ្ឈមណ្ឌលទំនាក់ទំនង EEC តាមរយៈលេខ 617-988-7841។

## សំណើនិងចម្លើយអំពីការបិទបញ្ចប់សំណើសុំត្រួតពិនិត្យតាមឆន្ទានុសិទ្ធិរបស់ស្ថាប័ន BRC

### 1. តើវាមានន័យដូចម្ដេចសម្រាប់បេក្ខជនដែលរកឃើញថា “មិនសមស្រប” ដោយសារតែការមិនឆ្លើយតបរបស់ពួកគេ? តើការសម្រេចលើភាពសមស្របត្រូវបានធ្វើឡើងដែរឬទេ?

បាទ/ចាស ការសម្រេចលើភាពសមស្របត្រូវបានធ្វើឡើង។ អនុលោមតាម 606 CMR 14.14(7) ស្ថាប័ន EEC ធ្វើការសម្រេចចិត្តថា "មិនសមស្រប " ដោយផ្អែកលើការមិនបានតបរបស់អ្នកដាក់ ពាក្យសុំ។ នៅពេលដែលបេក្ខជនម្នាក់ត្រូវបានរកឃើញថា "មិនសមស្រប" ដោយសារតែពួកគេ មិនបានឆ្លើយតប ពួកគេនឹងលែងទទួលបានការអនុញ្ញាតឱ្យធ្វើការនៅក្នុងកម្មវិធី ឬជាប់ទាក់ទង ជាមួយកម្មវិធីណាមួយផ្តល់អាជ្ញាប័ណ្ណឬមូលនិធិពីស្ថាប័ន EEC តទៅទៀត។ ប្រសិនបើបច្ចុប្បន្ន ពួកគេកំពុងធ្វើការនៅក្នុងកម្មវិធី ឬជាប់ទាក់ទងជាមួយកម្មវិធីដែលទទួលបានអាជ្ញាប័ណ្ណ ឬមូលនិធិពីកម្មវិធីណាមួយនោះ ពួកគេត្រូវតែបញ្ឈប់សកម្មភាពនោះក្នុងរយៈពេល 14 ថ្ងៃ។ ជាមួយនឹងបេក្ខជន FCC ពួកគេមិនអាចរស់នៅ ឬទៅលេងជាប្រចាំនៅលំនៅដ្ឋានរបស់កម្មវិធី FCC បានទេ ហើយអ្នកផ្តល់សេវា FCC មិនអាចបន្តបើកដំណើរការបានទេ នៅពេលដែលមានសមាជិកគ្រួសារ ឬមនុស្សស្ថិតនៅជាប្រចាំនៅក្នុងបរិវេណទីតាំង (ROP) ដែលពួគេត្រូវបានរកឃើញថា "មិនសមស្រប"។

### 2. តើបេក្ខជនស្នើសុំការបន្ថែមរយៈពេល 30 ថ្ងៃដើម្បីបញ្ចប់កម្មវិធី BRC របស់ពួកគេដោយរបៀបណា?

បេក្ខជនអាចទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនង EEC តាមរយៈលេខ 617-988-7841 ដើម្បីស្នើសុំការបន្ថែមរយៈពេល 30 ថ្ងៃ ដរាបណាពួកគេធ្វើការស្នើសុំក្នុងរយៈពេល 120 ថ្ងៃបន្ទាប់ពីត្រូវបានដាក់ ចូលទៅក្នុងការត្រួតពិនិត្យតាមឆន្ទានុសិទ្ធិ។ សំណើនីមួយៗត្រូវបានដោះស្រាយជាលក្ខណៈបុគ្គល។

### 3. តើបេក្ខជនដែលត្រូវបានគេរកឃើញថា "មិនសមស្រប" ដោយសារតែការមិនបានឆ្លើយតបរបស់ពួកគេ អាចដាក់ពាក្យសុំ BRC ម្តងទៀតបានដែរឬទេ?

ប្រសិនបើនេះជាលើកទីមួយដែលបេក្ខជនត្រូវបានរកឃើញថា “មិនសមស្រប” ដោយសារការមិនបានឆ្លើយតប ពួកគេអាចនឹងដាក់ពាក្យម្តងទៀតនៅពេលណាក៏បានដោយដាក់ជូនពាក្យស្នើសុំ BRC ថ្មី។ កម្មវិធីនឹងចាំបាច់ត្រូវទទួលបានទម្រង់បែបបទយល់ព្រមថ្មីដែលមានចុះហត្ថលេខាពីបេក្ខជនដែលពួកគេចង់បញ្ចូលម្តងទៀត។ បេក្ខជនដែលដាក់ពាក្យម្តងទៀត ត្រូវទូទាត់សងរាល់ថ្លៃសេវាដែលពាក់ព័ន្ធទាំងអស់។ បេក្ខជនទាំងអស់ដែលដាក់ពាក្យម្តងទៀត មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រភេទស្ថានភាពជាប់លក្ខខណ្ឌ ឬបណ្តោះអាសន្នណាមួយនោះទេ។ បេក្ខជនប្រភេទនេះ ត្រូវតែនៅក្រៅកម្មវិធី និង/ឬមិនជាប់ទាក់ទងជាមួយកម្មវិធីណាមួយ ខណៈពេលដែលពួកគេរង់ចាំ ការសម្រេចចិត្តសមស្រប។

**4. តើកម្មវិធីបញ្ចូលបេក្ខជនសាឡើងវិញដោយរបៀបណា ប្រសិនបើពួកគេត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ BRC Manager ជាលើកដំបូង?**

ឥឡូវនេះបេក្ខជនទាំងអស់ត្រូវតែបញ្ចូលតាមរយៈវិបផតថលកម្មវិធីរុករក BRC ។

**5. តើបេក្ខជនដែលត្រូវបានគេរកឃើញថា “មិនសមស្រប” ដោយសារតែការមិនបានឆ្លើយតបរបស់ពួកគេ អាចប្តឹងតវ៉ាលើលទ្ធផល “មិនសមស្រប” របស់ពួកបានដែរឬទេ?**

ទេ បេក្ខជនម្នាក់ដែលបានរកឃើញថា “មិនសមស្រប” ដោយសារការមិនឆ្លើយតបរបស់ពួកគេ **លើកដំបូង** នឹងមិនមានសិទ្ធិទទួលបានបណ្តឹងតវ៉ានោះទេ ព្រោះពួកគេអាចដាក់ពាក្យម្តងទៀតបានគ្រប់ពេល (សូមមើល 606 CMR 14.14(7))។

**5. តើមានអ្វីកើតឡើងបើបេក្ខជនបានដាក់ពាក្យសុំ BRC ហើយមិនបានបន្តនីតិវិធីជាច្រើនដង?**

ប្រសិនបើបេក្ខជនបានដាក់ពាក្យស្នើសុំ BRC ហើយមិនបានឆ្លើយតបទៅនឹងដំណើរការ BRC ច្រើនដង ពួកគេនឹងត្រូវបានរកឃើញថាមិនសមស្រប ហើយអាចត្រូវបានហាមឃាត់មិនឱ្យដាក់ពាក្យម្តងទៀតក្នុងរយៈពេល 3 ឆ្នាំ។ (សូមមើល 606 CMR §12177(e))។ បេក្ខជនម្នាក់មានសិទ្ធិប្តឹងតវ៉ាចំពោះបម្រាមរយៈពេលបីឆ្នាំនេះ។